**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ២៨៥២ ព.ណន..សពកព

ថ្ងៃចន្ទ ១២កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាពាណិជ្ជករ និងសាធារណជនទូទៅឱ្យបានជ្រាបថាប្រទេសអូស្ត្រាលី នឹងរៀបចំ "វេទិកាធុរកិច្ចអូស្ត្រាលី-អាស៊ាន ២០២៦" ក្រោមមូលបទ Deepening Australia-ASEAN Economic Integration in a Changing Global Landscape ពីថ្ងៃទី២៩-៣០ ខែកញ្ញា ឆ្នាំ២០២៦ នៅទីក្រុង Adelaide ប្រទេសអូស្ត្រាលី។ វេទិកានេះផ្តោតលើវិស័យអាទិភាពចំនួន ៥ រួមមាន ១)ថាមពល និងសន្តិសុខថាមពល ២)បរិវត្តកម្មឌីជីថល និងបញ្ញាសិប្បនិម្មិត ៣)ពាណិជ្ជកម្ម វិនិយោគ និងការតភ្ជាប់ខ្សែច្រវាក់ផ្គត់ផ្គង់ ៤)កសិកម្ម សន្តិសុខស្បៀង និងនិរន្តរភាព និង៥)ការអភិវឌ្ឍធនធានមនុស្ស និងជំនាញ ដោយនឹងមានអ្នកចូលរួមពីតំណាងរដ្ឋាភិបាល វិនិយោគិន និងថ្នាក់ដឹកនាំធុរកិច្ចប្រមាណជាង ១០០០នាក់។ ក្នុងន័យនេះ ប្រធានរៀបចំវេទិកាខាងលើ ស្នើអញ្ជើញវិស័យឯកជនកម្ពុជាចូលរួមតាំងពិព័រណ៍ផលិតផលក្នុងកម្មវិធីខាងលើ ដោយរាល់ចំណាយជាបន្ទុករបស់អ្នកចូលរួម។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមជាអ្នកសម្របសម្រួល សូមអញ្ជើញ លោក-លោកស្រី ជាពាណិជ្ជករ និងសាធារណជនទូទៅ ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងវេទិកាខាងលើ សូមធ្វើការទំនាក់ទំនងបំពេញបែបបទចូលរួមតាមរយៈនាយកដ្ឋានជំរុញពាណិជ្ជកម្ម និងកិច្ចការពិព័រណ៍ អគ្គនាយកដ្ឋានគោលនយោបាយ និងជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ឬតាមរយៈ QR code ខាងក្រោម។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកមន្ត្រីសម្របសម្រួល តាមរយៈទូរស័ព្ទលេខ +៨៥៥ ៨៦ ៣៣៣ ៩៣៣ / +៨៥៥ ៧៧ ៣៦១ ៨៣៦ ឬអ៊ីម៉ែល sorn.pitou@moc.gov.kh / oun.veasna@moc.gov.kh ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ១២៦៦៕

សម្រាប់ចុះឈ្មោះ:

**សូមអរគុណ!**

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469